ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា
គណៈកម្មាធិការលទ្ធកម្ម
លេខ:២៦៤៩ PC.អក

# សេចក្តីជូនដំណឹង
## ស្តីពី

ការងាររុះរើបន្ទប់ភ្លើងចាស់ៗ ចំនួន 05 បន្ទប់ភ្លើង និងសាងសង់ថ្មីឡើងវិញមានជាន់ផ្ទាល់ដី និងជាន់ទី 1 នៅលើទីតាំងចាស់ លេខ 300 (3.95m x 3.52m x 8.3m), លេខ 637 (4.50m x 4.45m x 8.3m), លេខ 015 (3.55m x 4.45m x 8.3m), លេខ 327 (4.4m x 4.32m x 8.3m), លេខ 396 (4.4m x 4.4m x 8.3m) ជូន អង្គភាពបណ្តាញ នៃនាយកដ្ឋានអាជីវកម្មចែកចាយ

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា ៖ អគ្គិសនីកម្ពុជា នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួលការងាររុះរើបន្ទប់ភ្លើងចាស់ៗ ចំនួន 05 បន្ទប់ភ្លើង និងសាងសង់ថ្មីឡើងវិញមានជាន់ផ្ទាល់ដី និងជាន់ទី 1 នៅលើទីតាំងចាស់ លេខ 300 (3.95m x 3.52m x 8.3m), លេខ 637 (4.50m x 4.45m x 8.3m), លេខ 015 (3.55m x 4.45m x 8.3m), លេខ 327 (4.4m x 4.32m x 8.3m), លេខ 396 (4.4m x 4.4m x 8.3m) ជូន អង្គភាពបណ្តាញ នៃនាយកដ្ឋានអាជីវកម្មចែកចាយ ។

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ ។ ឯកសារដេញថ្លៃមានដាក់លក់នៅអង្គភាពលទ្ធកម្មអគ្គិសនីកម្ពុជាដែលមានអាសយដ្ឋាន អាគារលេខ ២ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ចាប់ពីថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០២២ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ៖ 092 652 357 និង Website : www.edc.com.kh) ។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម យ៉ាងយូរបំផុតត្រឹមថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០២៣ វេលាម៉ោង ១៤:០០ ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋាន ខាងលើវេលាម៉ោង ១៥:០០ ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០២៣ ។

ក្រុមហ៊ុន/សហគ្រាសដែលចូលរួមដាក់ឯកសារដេញថ្លៃ ស្នើសុំភ្ជាប់បន្ថែមមកជាមួយនូវឯកសារដេញថ្លៃ ដែលបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម និងភ្ជាប់មកជាមួយនូវ Soft Copy ដែលជាឯកសារ Scan របស់ឯកសារដេញថ្លៃនេះ ។

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃចន្ទ ១១រោច ខែមិគសិរ ឆ្នាំ ខាល ចត្វាស័ក ព.ស២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០២២
ឋ-ប្រធានគណៈកម្មាធិការលទ្ធកម្ម

[illegible]

ចម្លងជូន ៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារ-កាលប្បវត្តិ